ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងព្រហ្មទណ្ឌលេខ: ៧៣៩ អក
ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៩
សាលក្រមលេខ៖ ០៨១ (ណ)
ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

-បានបើកសវនាការជំនុំជម្រះសាធារណៈ នៅសាលាដំបូងខេត្តកណ្តាល នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ ដោយមានសមាសភាពដូចតទៅ:

**សមាសភាពជំនុំជំរះ**

លោក [redacted] ចៅក្រមជំនុំជម្រះ

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជី សាលាដំបូងខេត្តកណ្តាល

លោក [redacted] មេធាវីការពារក្តីឱ្យឈ្មោះ:[redacted]ផល្លី

**ដើម្បីជំនុំជំរះ** សំណុំរឿងព្រហ្មទណ្ឌលេខ: **៧៣៩ អក** ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៩ ដែលមាន**ជនជាប់ចោទ** ៖

-ឈ្មោះ: [redacted] **ផល្លី** ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ន នៅភូមិ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ: [redacted]**សុផល** (រស់) ម្តាយឈ្មោះ: [redacted] **យឿន** (រស់) ប្រពន្ធឈ្មោះ:[redacted]**ចាន់ធា** (រស់) មានកូន ០១នាក់ ជានីតិជន ទោសពីមុនគ្មាន ។

-ជនត្រូវចោទឈ្មោះ: [redacted] **ផល្លី** ត្រូវក្រមស៊ើបសួរចេញដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ: **១៥៧៦** ដកបឃខ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៩។

-ជនត្រូវចោទឈ្មោះ: [redacted] **ផល្លី** ត្រូវក្រមស៊ើបសួរចេញដីកាសម្រេចអនុញ្ញាតឱ្យជនត្រូវចោទនៅក្រៅឃុំខ្លួនបណ្តោះអាសន្នលេខ: **២៨០៥** ដកក្រយ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩។

ត្រូវជាប់ចោទពីបទ: **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិសាមគ្គី ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ បញ្ញត្តិផ្តន្ទាទោសតាមមាត្រា **២១៧ នៃក្រមព្រហ្មទណ្ឌ**។

**-ដើមបណ្តឹងរដ្ឋប្បវេណី** ឈ្មោះ:[redacted]**សុផល** ភេទប្រុស អាយុ ៥៦ឆ្នាំ ជនជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើត និងទីបច្ចុប្បន្ននៅភូមិសាមគ្គី ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល ឪពុកឈ្មោះ: [redacted]បួន (ស្លាប់) ម្តាយឈ្មោះ គោ (រស់) ប្រពន្ធឈ្មោះ: [redacted] **យឿន** (រស់) មានកូន ០២នាក់ ជានីតិជន ទោសពីមុនគ្មាន ។

**ការប្រព្រឹត្តរបស់ជនជាប់ចោទ**

ស្រីណា



Scanned with CamScanner

កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង១៧ និង៣០នាទី ស្ថិតនៅភូមិសាមគ្គី ឃុំព្រៃដំបង ស្រុកមុខកំពូល ខេត្តកណ្តាល ជនសង្ស័យឈ្មោះ [redacted] ផល្លី បានផឹកស្រាជាមួយមិត្តភ័ក្រ្តរួចក៏បានឈ្លោះជាមួយ ប្រពន្ធឈ្មោះ [redacted] ចាន់ធា ភ្លាមនោះជនសង្ស័យបានយកទំពូករនាស់គប់គំរាបប្រពន្ធ ជួនពេលនោះឪពុករបស់ ជនសង្ស័យឈ្មោះ [redacted] សុផល បានដើរមកដល់ក៏ត្រូវចំលើចុងចិញ្ចើមខាងស្តាំបណ្តាលឱ្យបែកចេញឈាម បន្ទាប់ មកសត្តកិច្ចមកដល់ រួចក៏បានឃាត់ខ្លួនជនសង្ស័យតែម្តង។

ដោយ**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ **១១៨៧** ដកសព ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ របស់តំណាង អយ្យការអមសាលាដំបូងខេត្តកណ្តាល ។

**បានឃើញ** ដីកាដំណោះស្រាយលេខ **១២៩០** ដកជស ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩ របស់ចៅក្រមស៊ើសួរ សាលា ដំបូងខេត្តកណ្តាល ។

**បានឃើញ** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ **១៣៣៩** ដកចត ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ របស់ ប្រធានសាលាដំបូងខេត្តកណ្តាល ។

## <u>អង្គហេតុដែលបានលើកឡើងនាពេលសវនាការ</u>

១-អានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ផល្លី បានឆ្លើយអះអាងថាៈ កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ២០១៩ វេលាម៉ោង ៥,០០នាទី ល្ងាចខ្លួនបាននាំគ្នាមកផឹកស្រាថ្នាំ ជាមួយឈ្មោះ **ប៉ែត** ,ឈ្មោះ **ភឿន** និងឈ្មោះ **ហើម** រហូតដល់ម៉ោង ៥ និង៣០នាទីល្ងាច នៅក្រោមផ្ទះរបស់ខ្លួន ហើយប្រពន្ធក៏បានទៅជេរស្តីបន្ទោសខ្លួន ហើយ ក៏បែកវង្សគ្នាឈប់ផឹក ខ្លួនក៏ដើរមកផ្ទះដោយខឹងប្រពន្ធក៏ឈ្លោះប្រកែកគ្នាឈាម រួចឪពុកខ្លួនក៏ទៅប្តឹងសមត្ថកិច្ចប៉ុស្តិ៍ យកខ្លួន ទៅសាកសួរតែម្តង។ ខ្លួនយកទំពូករនាស់គប់ទៅលើប្រពន្ធស្របពេលនោះ ឪពុកខ្លួនដើរមកដល់បណ្តាល ឱ្យត្រូវចុងចិញ្ចើមខាងស្តាំ

២-អានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុផល** បានឆ្លើយអះអាងថាៈ កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង១៧ និង៣០នាទី កូនខ្លួនឈ្មោះ [redacted] **ផល្លី** បានផឹកស្រវឹងមកឈ្លោះប្រកែកគ្នាជា មួយប្រពន្ធនៅក្រោមផ្ទះខ្លួន ហើយនិងប្រពន្ធបានឃាត់វាពីរនាក់កុំឱ្យឈ្លោះគ្នា ប៉ុន្តែពួកវាមិនស្តាប់ភ្លាមនោះកូនខ្លួន ឈ្មោះ [redacted] **ផល្លី** បានយកទំពូករនាស់គុបទៅ ប្រពន្ធតែប្រពន្ធវាគេចផុតបណ្តាលឱ្យត្រូវខ្លួនចំចិញ្ចើមខាងស្តាំង មាន របួសបែកឈាមក្នុងសកម្មភាពនេះខ្លួន និងកូននាំគ្នាចាប់វាចង់នៅលើគ្រែក្រោមផ្ទះ ដើម្បីឱ្យវាស្ងាងរហូតដល់ម៉ោង ប្រហែលជាង ៩ យប់ ប្រពន្ធខ្លួនបានតេទៅកូនស្រីឈ្មោះ ផល្លា រួចមកកូនស្រីបានតេទូរស័ព្ទហាវសមត្ថកិច្ចប៉ុស្តិ៍ ព្រែកដំបង ឱ្យមកយកជនសង្ស័យដែលជាកូនរបស់ខ្លួនយកទៅប៉ុស្តិ៍តែម្តង។

៣-អានចម្លើយរបស់សាក្សីឈ្មោះ [redacted] **ចាន់ធា** ភេទស្រី អាយុ ៣២ឆ្នាំ (ត្រូវជាប្រពន្ធជនសង្ស័យ) បានឆ្លើយ អះអាងថា នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង០៣ល្ងាច ប្តីខ្លួនបានសុំលុយម្តាយក្មេកខ្លួនចំនួនប្រាំពាន់ រៀល ទៅទិញស្រាផឹក លុះដល់ម៉ោងបួនល្ងាចទើបប្តីខ្លួនមកពីកន្លែងផឹកស៊ីវិញ ចូលផ្ទះក៏មានការជេជែករករឿងជា មួយខ្លួន ថាខ្លួនមានសាហាយស្មន់ ហើយរកវាយដំមកលើខ្លួន ប៉ុន្តែខ្លួនចេះដើរគេច ហើយក៏យកកូនទៅបញ្ចុកបាយ ភ្លាមនោះក៏មានការប្រតប់គ្នាជាមួយខ្លួនម្តាយក្មេក និងឪពុកក្មេកក៏បានចូលមកជួយពេលនោះប្តីខ្លួន បានទាញ់ទំពក់ ឬស្សីគប់មកលើខ្លួន ប៉ុន្តែមិនត្រូវខ្លួន ក៏ត្រូវចំចិញ្ចើមខាងស្តាំងបណ្តាលឱ្យមានរបួសចេញឈាម ហើយក៏នាំគ្នាចាប់ ប្តីខ្លួនចង់រួចម្តាយក្មេកខ្លួនតេទៅប្អូនថ្លៃនៅឯភ្នំពេញឱ្យជួយគេប្រាប់ប៉ូលីស ដើម្បីមកជួយអន្តរាគមន៍ មួយស្ទុះក្រោយ មកក៏ឃើញមានសមត្ថកិច្ចមកដល់ ក៏ធ្វើការនាំខ្លួនប្តីខ្លួនទៅម្តង។

៤-អានចម្លើយរបស់សាក្សីឈ្មោះ [redacted] **ឃឿន** ភេទស្រី អាយុ ៦០ឆ្នាំ (ត្រូវជាប្រពន្ធជនរងគ្រោះ) បានឆ្លើយ អះអាងថាៈ នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ នៅវេលាម៉ោង ១២ និង០០នាទី កូនខ្លួនឈ្មោះ [redacted] ផល្លី បានចេញ

ពីផ្ទះទៅផឹកស្រាជាមួយមិត្ត នៅចំណុចកុំម្ពុប្ញស្សីក្រោយផ្ទះ ដោយសុំប្រាក់ខ្លួនចំនួន៥០០០(ប្រាំពាន់) រៀល។ ដល់វេលាម៉ោង០២ រសៀល ក៏ដើរ មកផ្ទះវិញមានសភាពរាងស្រវឹង ហើយក៏បានឈ្លោះប្រកែកគ្នាជាមួយ ប្រពន្ធ ហើយខ្លួនបានឃាត់វាក៏ស្ងាត់មាត់បាន បន្តិចក៏ដើរទៅកន្លែងផឹកវិញ។ រហូតដល់ម៉ោង៤ ល្ងាចវាក៏មកម្ដងទៀតដោយមានសភាពស្រវឹងខ្លាំងគំរាមវាយប្រពន្ធ ហើយខ្លួនតាមឃាត់កូនរហូតមិន ឈ្លោះគ្នាស្រាប់តែដល់ប្រហែលម៉ោង៥ ល្ងាចជាងវាក៏បានឃើញទំពូកនាស់នៅ ក្រោមគ្រែក៏ស្ទុះយកមកគំរាមប្រពន្ធស្របជាមួយគ្នានោះប្ដីខ្លួន ក៏ដើរមកពីច្រូតស្មៅវិញបណ្ដាលឱ្យត្រូវចំញើមខាង ស្ដាំងបែកឈាម ឃើញដូចច្នេះខ្លួននិងកូន និងប្ដីក៏ចាប់វា ចង់ជាប់និងគ្រែរហូតដល់ម៉ោង ៩ យប់ក៏តេប្រាប់កូនស្រី ឈ្មោះ [redacted] **ផល្លា** ឱ្យប្រាប់ប៉ូលីស ឱ្យយកវាទៅប៉ុស្ដិ៍ដល់ម៉ោងប្រហែល ១០ យប់ទើបឃើញសមត្ថកិច្ចប៉ុស្ដិ៍មកដល់ ហើយយកកូនឈ្មោះ [redacted] ផល្លី ទៅប៉ុស្ដិ៍តែម្ដង។

៥-សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ ឆ្លងតាមអង្គសវនាការនេះ តំណាងអយ្យការយល់ឃើញថា៖ កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ នៅចំណុចភូមិសាមគ្គី ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល ពិតជាមានអង្គហេតុ **ហិង្សាដោយចេតនា** បង្កឡើងដោយឈ្មោះ [redacted] **ផល្លី** ពិតប្រាកដមែន។

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់

## សាលាដំបូងខេត្តកណ្ដាល
## យល់ឃើញថា

**ក.អំពីពិរុទ្ធភាព៖**

១-តាមដីកាដំណោះស្រាយលេខ៖ ១២៩០ អក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩ របស់ ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] **ផល្លី** មកតុលាការ ដើម្បីជំនុំជម្រះពីបទ៖ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិសាមគ្គី ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ តាមបញ្ញត្តិផ្ដន្ទាទោសតាមមាត្រា **២១៧ នៃក្រមព្រហ្មទណ្ឌ** ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ផល្លី បានឆ្លើយអះអាងថា៖ កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង ៥,០០នាទី ល្ងាចខ្លួនបាននាំគ្នាមកផឹកស្រាថ្នាំ ជាមួយឈ្មោះ **ប៉ែត** ,ឈ្មោះ **ភឿន** និងឈ្មោះ **ហើម** រហូតដល់ម៉ោង ៥ និង៣០នាទីល្ងាច នៅក្រោមផ្ទះរបស់ខ្លួន ហើយប្រពន្ធក៏បានទៅជេរស្ដីបន្ទោសខ្លួន ហើយក៏បែកវង្សត្មាឈប់ផឹក ខ្លួនក៏ដើរមកផ្ទះដោយខឹងប្រពន្ធក៏ឈ្លោះប្រកែកគ្នាឈាម រួចឪពុកខ្លួនក៏ទៅប្ដឹងសមត្ថកិច្ចប៉ុស្ដិ៍យកខ្លួន ទៅសាកសួរតែម្ដង។ ខ្លួនយកទំពូករនាស់គប់ទៅលើប្រពន្ធស្របពេលនោះ ឪពុកខ្លួនដើរមកដល់បណ្ដាលឱ្យត្រូវចុងចិញ្ចើមខាងស្ដាំ

៣-តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុផល** បានឆ្លើយអះអាងថា៖ កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង១៧ និង៣០នាទី កូនខ្លួនឈ្មោះ [redacted] **ផល្លី** បានផឹកស្រវឹងមកឈ្លោះប្រកែកគ្នាជាមួយប្រពន្ធនៅក្រោមផ្ទះខ្លួន ហើយនិងប្រពន្ធបានឃាត់វាពីរនាក់កុំឱ្យឈ្លោះគ្នា ប៉ុន្តែពួកវាមិនស្ដាប់ភ្លាមនោះកូនខ្លួនឈ្មោះ [redacted] **ផល្លី** បានយកទំពូករនាស់គប់ទៅ ប្រពន្ធតែប្រពន្ធវាគេចផុតបណ្ដាលឱ្យត្រូវខ្លួនចំចិញ្ចើមខាងស្ដាំង មានរបួសបែកឈាមក្នុងសកម្មភាពនេះខ្លួន និងកូននាំគ្នាចាប់វាចង់នៅលើគ្រែក្រោមផ្ទះ ដើម្បីឱ្យវាស្ងាងរហូតដល់ម៉ោងប្រហែលជាង ៩ យប់ ប្រពន្ធខ្លួនបានតេទៅកូនស្រីឈ្មោះ ផល្លា រួចមកកូនស្រីបានតេទូរស័ព្ទហាវសមត្ថកិច្ចប៉ុស្ដិ៍ព្រែកដំបង ឱ្យមកយកជនសង្ស័យដែលជាកូនរបស់ខ្លួនយកទៅប៉ុស្ដិ៍តែម្ដង។



Scanned with CamScanner

៤-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ចាន់ធា ភេទស្រី អាយុ ៣២ឆ្នាំ (ត្រូវជាប្រពន្ធជនសង្ស័យ) បានឆ្លើយ អះអាងថា នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង០៣ល្ងាច ប្ដីខ្លួនបានសុំលុយម្ដាយក្មេកខ្លួនចំនួនប្រាំពាន់ រៀល ទៅទិញស្រាផឹក លុះដល់ម៉ោងបួនល្ងាចទើបប្ដីខ្លួនមកពីកន្លែងផឹកស៊ីវិញ ចូលផ្ទះក៏មានការជជែករឿងជា មួយខ្លួន ថាខ្លួនមានសាហាយស្មន់ ហើយវាយដំមកលើខ្លួន ប៉ុន្តែខ្លួនចេះដឹរគេច ហើយក៏យកកូនទៅបញ្ចុកបាយ ភ្លាមនោះក៏មានការប្រកាប់គ្នាជាមួយ ខ្លួនម្ដាយក្មេក និងឪពុកក្មេកក៏បានចូលមកជួយពេលនោះប្ដីខ្លួន បានទាញ់ទំពក់ឬស្សីគប់មកលើខ្លួន ប៉ុន្តែមិនត្រូវខ្លួន ក៏ត្រូវចំចិញ្ចើម ខាងស្ដាំងបណ្ដាលឱ្យមានរបួសចេញឈាម ហើយក៏នាំគ្នាចាប់ ប្ដីខ្លួនចង់រួចម្ដាយក្មេក ខ្លួនតេទៅប្អូនថ្លៃនៅ ឯភ្នំពេញឱ្យជួយតេប្រាប់ប៉ូលីស ដើម្បីមកជួយអន្តរាគមន៍ មួយស្នុះក្រោយមកក៏ឃើញមានសមត្ថកិច្ចមកដល់ ក៏ធ្វើការនាំខ្លួនប្ដីខ្លួនទៅម្ដង។

៥-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] យឿន ភេទស្រី អាយុ ៦០ឆ្នាំ បានឆ្លើយអះអាងថា៖ នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ នៅវេលាម៉ោង ១២ និង០០នាទី កូនខ្លួនឈ្មោះ [redacted] ផល្លី បានចេញ ពីផ្ទះទៅផឹកស្រាជាមួយមិត្ត នៅចំណុចកុំម្ព ឬស្សីក្រោយផ្ទះ ដោយសុំប្រាក់ខ្លួនចំនួន៥០០០(ប្រាំពាន់) រៀល។ ដល់វេលាម៉ោង០២ រសៀល ក៏ដើរមកផ្ទះ វិញមានសភាពាងស្រវឹង ហើយក៏បានឈ្លោះប្រកែកគ្នាជាមួយប្រពន្ធហើយ ខ្លួនបានឃាត់វាក៏ស្ងាត់មាត់បាន បន្តិចក៏ដើរទៅកន្លែងផឹកវិញ។ រហូតដល់ម៉ោង៤ ល្ងាចវាក៏មកមួយដង ទៀតដោយ មានសភាពស្រវឹងខ្លាំងគំរាមវាយប្រពន្ធ ហើយខ្លួនតាមឃាត់កូនរហូតមិនឈ្លោះគ្នាស្រាប់តែដល់ប្រហែល ម៉ោង៥ ល្ងាច ជាងវាក៏បានឃើញទំពូកនាស់នៅ ក្រោមគ្រែក៏ស្ទុះយកមកគំរាមប្រពន្ធស្រប ជាមួយគ្នានោះប្ដីខ្លួន ក៏ដើរមកពីច្រូតស្មៅ វិញបណ្ដាលឱ្យត្រូវចំញើមខាងស្ដាំងបែកឈាម ឃើញដូចច្នេះខ្លួននិងកូន និងប្ដីក៏ចាប់វាចង់ជាប់ និងគ្រែរហូតដល់ ម៉ោង ៩ យប់ក៏តេប្រាប់កូនស្រី ឈ្មោះ [redacted] ផល្លា ឱ្យប្រាប់ប៉ូលីស ឱ្យយកវាទៅប៉ុស្តិ៍ ដល់ម៉ោងប្រហែល ១០ យប់ទើប ឃើញសមត្ថកិច្ចប៉ុស្តិ៍មកដល់ ហើយយកកូនឈ្មោះ [redacted] ផល្លី ទៅប៉ុស្តិ៍តែម្ដង។

៧-តាមរបាយការណ៍របស់មន្ត្រីនគរបាលបញ្ជាក់ថា នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ នៅចំណុចភូមិសាមគ្គី ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល ពិតជាមានអង្គហេតុ៖ **ហិង្សាដោយចេតនា** បង្កឡើងដោយឈ្មោះ [redacted] ផល្លី ។

៨-តំណាងអយ្យការបានសន្និដ្ឋានថា៖ កាលពីថ្ងៃទី១៤ ខែមិថុនាម ឆ្នាំ២០១៩ នៅចំណុចភូមិសាមគ្គី ឃុំ ព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល ពិតជាមានអង្គហេតុ **ហិង្សាដោយចេតនា** បង្កឡើងដោយឈ្មោះ [redacted] ផល្លី ពិតប្រាកដមែន។ ដូច្នេះតំណាងអយ្យការសូមដំកល់បទចោទនេះនៅដដែល តាមដីកាសន្និដ្ឋានស្ថាពរលេខ៖ **១១៨៧** ដកសព ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ នៅចំណុចភូមិសាមគ្គី ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល បាន ប្រព្រឹត្តបទ៖ **ហិង្សាដោយចេតនា** តាមបញ្ញត្តិផ្ដន្ទាទោសតាមមាត្រា **២១៧ នៃក្រមព្រហ្មទណ្ឌ** ជាមូលដ្ឋាន ។

-**មេធាវីឈ្មោះ** [redacted] ជាមេធាវីការពារសិទ្ធឱ្យជនជាប់ចោទឈ្មោះ [redacted] **ផល្លី បានធ្វើការសន្និដ្ឋានថា៖** ឆ្លងតាមអង្គសវនាការស្ដាប់ចំម្លើយនេះ កូនក្ដីរបស់នាងខ្ញុំ បានឆ្លើយសារភាពថាខ្លួន ពិតជាបានប្រើអំពើ **ហិង្សាដោយចេតនា** ទៅលើកជនរងគ្រោះបណ្ដាលឱ្យមានរបួសពិតប្រាកដមែន។ ហេតុដូចច្នេះក្នុងនាមនាងខ្ញុំ មេធាវីការពារសិទ្ធឱ្យជនជាប់ចោទ សូមស្នើសុំដល់លោកចៅក្រមមេត្តា ជួយបន្ធូរបន្ថយទោស ឱ្យកូនក្ដីនាងខ្ញុំផង។

៩-តាមចម្លើយរបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី របាយការណ៍របស់មន្ត្រីនគរបាល និងការសន្និដ្ឋានរបស់តំណាងអយ្យការ និងមានភាពស៊ីសង្វាក់គ្នាអាចបញ្ជាក់បានថា ដោយជនជាប់ឈ្មោះ [redacted] ផល្លី ពិតជាបានយកទំពូកនាស់ធ្វើអំពីឫស្សីក្រវាស់ដើម្បីគំរាមប្រពន្ធខ្លួន តែក៏ត្រូវឪពុករបស់ខ្លួនចំចិញ្ចើមខាងស្ដាំ បណ្ដាលឱ្យមានរបួសចេញឈាមប្រាដកមែន ពិតជាមានអង្គហេតុនៃបទ **ហិង្សាដោយចេតនា** កើតឡើងនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ ចំណុចភូមិសាមគ្គី ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្ដាល ។

១០-អំពើរបស់ជនជាប់ចោទ បានធ្វើឲ្យខូចប្រយោជន៍របស់អ្នកដទៃដែលច្បាប់បានការពារ និងធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ របៀបរៀបរយសណ្ដាប់ធ្នាប់សាធារណៈ និងសង្គម ដែលជាអំពើបំពានលើច្បាប់ មានចែឱ្យផ្ដន្ទាទោស

តាមបញ្ញាត្តិមាត្រា **២១៧** នៃ**ក្រមព្រហ្មទណ្ឌ**។

១១-ជនជាប់ចោទឈ្មោះ [redacted] ផល្លី ភេទប្រុស អាយុ ៣០ឆ្នាំ ជានីតិជនមានស្មារតី និងត្រូវគ្រប់គ្រាន់ក្នុងការសត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ហើយមានចេតនាពិតប្រាកដក្នុងការប្រព្រឹត្តខាងលើ។

១២-មានភស្តុតាង ដាក់បន្ទុកគ្រប់គ្រាន់បញ្ជាក់ពីពិរុទ្ធភាពលើៈ ឈ្មោះ [redacted] ផល្លី ភេទប្រុស អាយុ ៣០ឆ្នាំ ពីបទៈ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិសាមគ្គី ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី១៤ ខែ មិថុនា ឆ្នាំ២០១៩ តាមបញ្ញត្តិផ្តន្ទាទោសតាមមាត្រា **២១៧** នៃក្រមព្រហ្មទណ្ឌ ។

១៣-វត្ថុតាងចាប់យកបាន

-ទំពួករនាស់ធ្វើអំពីឬស្សីចំនួន ០១ ប្រវែង ០.៦០ម ទំហំ ០.៧០ (រៀងអក្សរជេ(J)

-គូរប្លង់កន្លែងកើតហេតុចំនួន ០១ច្បាប់

-ថតរូបនៅកន្លែងហេតុចំនួន ០១ ក្បាល

## ហេតុដូច្នេះ សាលាដំបូងខេត្តកណ្តាលវិនិច្ឆ័យសេចក្តី

**១-ផ្តន្ទាទោសលើជនជាប់ចោទដូចខាងក្រោមៈ**

១.១-ឈ្មោះ [redacted] ផល្លី ភេទប្រុស (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារ កំណត់រយៈពេល ០១ (មួយ)ឆ្នាំអនុវត្តរយៈពេលឃុំខ្លួន តែទោសនេះត្រូវអនុវត្តព្យួរ និងវិន័យជាប្រាក់ចំនួន ២,០០០,០០០ (ពីរ)លានរៀល ដាក់ចូលជាថវិការដ្ឋ។

ពីបទៈ **ហិង្សាដោយចេតនា** ប្រព្រឹត្តនៅភូមិសាមគ្គី ឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩ តាមបញ្ញត្តិផ្តន្ទាទោសតាមមាត្រា **២១៧** នៃក្រមព្រហ្មទណ្ឌ ។

២-សាលក្រមនេះជំនុំជំរះនិងប្រកាស ជាសាធារណៈថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០ ដោយកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ផល្លី និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សុផល ហើយក៏ជាជនរងគ្រោះដែល។

ទុកសិទ្ធិឲ្យប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជំរះ**
**ហត្ថលេខា និងត្រា** | **ហត្ថលេខា និងត្រា**
[redacted] | [redacted]

---

( បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម )

ថ្ងៃទី..[illegible]..០៦កើត..ខែ..ពិសាខ......ឆ្នាំជូត ទោស័ក ព.ស២៥៦៣

កណ្តាល,ថ្ងៃទី....២៧.....ខែ..មេសា..... ឆ្នាំ២០១៩

**បានឃើញ** | **ក្រឡាបញ្ជី**

**ចៅក្រម**

[redacted] | [redacted]

**បានទទួលដំណឹង**

ថ្ងៃ..អង្គារ...០៧កើត.... ខែ..ពិសាខ... ឆ្នាំជូត ទោស័ក ព.ស ២៥៦៣

កណ្តាល,ថ្ងៃ.......... ខែ..មេសា.. ឆ្នាំ២០២០

**តំណាងអយ្យការ**

ស្រីណា

[redacted]

ព្រះរាជអាជ្ញារង